01329101

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 09 / 2016
ម៉ោង (Time/Heure): 14 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E443

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**Declassified to Public**
**05 April 2019**

សម្ងាត់ Confidential / Confidentiel

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៦

**ជូនចំពោះ៖** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖** **ចៅក្រម យ៉ា សុខន ជ.ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម, មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖** **សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា សុំឱ្យស្តាប់សក្ខីកម្មសាក្សីបន្ថែម អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E391, E392, E395, E412 និង E426)**

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើចំនួន ៥ ពីមេធាវីការពារក្តី នួន ជា សុំឱ្យស្តាប់សាក្សីបន្ថែម អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដោយស្នើសុំឱ្យអង្គជំនុំជម្រះពន្លឿនការស្តាប់សក្ខីកម្មសាក្សីដែលត្រូវបានស្នើសុំពីពេលមុន និង សុំការពិចារណាឡើងវិញលើសេចក្តីសម្រេចពីមុនៗរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានសម្រេចមិនស្តាប់សក្ខីកម្មសាក្សីមួយចំនួន (ឯកសារ E391, E392, E395, E412 និង E426)។ ដោយពិចារណាទៅលើសំអាងហេតុនានាដែលមេធាវីការពារក្តីបានដាក់ និង ការឆ្លើយតបពីភាគីផ្សេងទៀត អង្គជំនុំជម្រះ៖

**យល់ព្រមតាម** សំណើសុំស្តាប់សក្ខីកម្ម ជាល ជឿន (2-TCW-960), ហួន ជឿម (2-TCW-1037), ឈន វន (2-TCW-1036), សែម អំ (2-TCW-1031), ឡុង វុន

(2-TCW-971), ទេស អុល (2-TCW-1060), មាស សឿន (2-TCW-917), ស៊ួយ សៅ (2-TCW-1029), នឹម គីមស្រ៊ាង (2-TCW-854) និង ម៉ី សាវឿន (2-TCCP-1040)។

**រម្លឹកថា** ទាត់ ធឿន (2-TCW-829), ម៉ម ណៃ (2-TCW-864), អន សុភាព (2-TCW-1041) និង លី ហ៊ី (2-TCW-956) បានទទួលមរណភាពហើយ។

**កត់សម្គាល់ថា** អង្គជំនុំជម្រះបានស្នើសុំព័ត៌មានពី Walter HEYNOWSKI (2-TCW-946) ទាក់ទិននឹងការដឹងរបស់គាត់អំពីឯកសារពាក់ព័ន្ធនានាជំនួសឲ្យការស្តាប់សក្ខីកម្មរបស់គាត់។

**ពន្យារ** ការចេញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅលើករណីថា តើគួរ ឬ មិនគួរស្តាប់សក្ខីកម្មរបស់ 2-TCW-831, 2-TCW-951 និង 2-TCW-962។

**ពន្យារបន្ថែមទៀត** ក្នុងការចេញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅលើករណីថា តើគួរ ឬ មិនគួរស្តាប់សក្ខីកម្មរបស់ ហ៊ិន សុផានី (2-TCW-1042) រហូតដល់ពេលដែលអង្គជំនុំជម្រះទទួលបានព័ត៌មានបន្ថែមពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

**បដិសេធ** សំណើសុំផ្សេងៗទៀត។

២. សំអាងហេតុពេញលេញនៃសេចក្តីសម្រេចនេះនឹងត្រូវចេញក្នុងពេលវេលាសមស្របខាងមុខ។